# ស្ថានភាពអតិផរណានៅខែមិថុនា ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែមិថុនា នេះ មានការកើនឡើង **0,១%** ធៀបនឹងខែមុន ឬ **២,៩%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើប្រៀបធៀបនឹងខែមេសា ឆ្នាំ២០១៧, សន្ទស្សន៍ថ្លៃទំនិញ ភាគច្រើនមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលក្នុងនោះមានដូចជា សន្ទស្សន៍ថ្លៃអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង, សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់, សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និងស្បែកជើង, សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត, សន្ទស្សន៍ថ្លៃសុខាភិបាល, សន្ទស្សន៍ថ្លៃការដឹកជញ្ជូន និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន។

បើទោះបីជាសន្ទស្សន៍ថ្លៃទំនិញភាគច្រើនហាក់មាននិន្នាការកើនឡើងវិញ, ប៉ុន្តែ កំណើនសន្ទស្សន៍ថ្លៃទំនិញជាមធ្យមក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ មានអត្រា (២,៥%) ទាបជាងកំណើនជាមធ្យមក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (៣,៥%)។ ដោយផ្អែកលើកំណើនជាមធ្យមក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ, យើងអាចសន្និដ្ឋានបានថា ស្ថានភាពអតិផរណាក្នុងឆ្នាំ២០១៨ នៅតែរក្សាបានស្ថិរភាពល្អ ពោលគឺស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន។ ការរក្សាបានអត្រាកំណើនទាបនេះ ដោយសារការថមថយកំណើនសន្ទស្សន៍ថ្លៃក្រុមទំនិញម្ហូបអាហារនាពេលដើមឆ្នាំ បើទោះបីជាថ្លៃប្រេងឥន្ធនៈមាននិន្នាការងើបឡើងវិញបន្តិចក៏ដោយ។ *តាមការធ្វើចំណោលដល់ខែធ្នូ ឆ្នាំ ២០១៨ អតិផរណាប្រចាំឆ្នាំ (year on year) អាចនឹងមានអត្រា ២,៨% ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចនឹងមានអត្រា ២,៧%។*

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **+0,១** | **+២,៩** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +0,២ | +៣,២ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +0,២ | +១,៩ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | +0,៥ | +២,៧ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | -0,១ | +១,៥ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | -0,១ | +0,៤ |
| ៦-សុខាភិបាល | 0,0 | +១,៦ |
| ៧-ការដឹកជញ្ជូន | +0,៣ | +៤,៩ |
| ៨-គមនាគមន៍ | -0,១ | -0,២ |
| ៩-ការកំសាន្ត និងវប្បធម៌ | +0,៦ | -0,៤ |
| ១0-ការសិក្សា | 0,0 | -0,៤ |
| ១១-ភោជនីយដ្ឋាន | +0,២ | +៤,៣ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | 0,0 | +៣,៤ |

| តារាង ១ ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | | | ២០១៨ | | |
| | មេសា | ឧសភា | មិថុនា | មេសា | ឧសភា | មិថុនា |
| អង្ករ | +0,១ | +0,៣ | +0,៣ | +២,៣ | +២,៦ | +២,៣ |
| សាច់គោ | +0,៧ | +0,៥ | -0,៥ | +៣,៥ | +៤,២ | +៤,0 |
| សាច់មាន់ | +១,0 | +0,៣ | +0,៣ | +១,0 | +៣,១ | +២,៧ |
| សាច់ទា | +0,៥ | -0,១ | -0,៤ | +១,៤ | +២,៤ | +២,៤ |
| សាច់ជ្រូក | +0,៥ | -0,១ | +0,២ | +0,២ | +១,៣ | +១,៦ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +0,៦ | +0,៨ | +0,៤ | +៤,0 | +៥,៣ | +៤,៩ |
| ក្នុងនោះត្រីស្រស់ | +0,៦ | +១,0 | +0,៤ | +៤,៣ | +៥,៦ | +៤,៩ |
| ផ្លែឈើ | +១,៧ | -0,៧ | +0,២ | +៣,៥ | +៣,៨ | +៣,៦ |
| ផ្លែឈើស្រស់ | +២,0 | -0,៨ | +0,២ | +២,៧ | +៣,៥ | +៣,៧ |
| បន្លែ | +១,៣ | +0,៨ | +0,១ | +0,៩ | +៣,១ | +៥,១ |
| បន្លែជាស្លឹក | +១,៤ | +0,៩ | +0,៨ | +១,៨ | +៤,៣ | +៧,៤ |
| បន្លែជាផ្លែ | +១,៨ | +0,៤ | -0,៦ | +0,៥ | +៣,១ | +៥,៣ |

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៧ | | | | ២០១៨ | | | |
| | មីនា | មេសា | ឧសភា | មិថុនា | មីនា | មេសា | ឧសភា | មិថុនា |
| ប្រទេសកម្ពុជា | 4.3 | 3.2 | 2.5 | 2.3 | 2.3 | 2.4 | 2.9 | 2.9 |
| ប្រទេសវៀតណាម | 4.7 | 4.3 | 3.2 | 2.5 | 2.7 | 2.8 | 3.9 | 4.7 |
| ប្រទេសថៃ | 0.76 | 0.4 | 0.0 | -0.1 | 0.79 | 1.07 | 1.49 | 1.38 |
| ប្រទេសម៉ាឡេស៊ី | 5.1 | 4.4 | 3.9 | 3.6 | 1.3 | 1.4 | 1.8 | 0.8 |
| ប្រទេសឥណ្ឌូនេស៊ី | 3.6 | 4.2 | 4.3 | 4.4 | 3.4 | 3.4 | 3.2 | 3.1 |
| ប្រទេសហ្វីលីពីន | 3.1 | 3.2 | 2.9 | 2.5 | 4.3 | 4.5 | 4.6 | 5.2 |
| ប្រទេសចិន | 0.9 | 1.2 | 1.5 | 1.5 | 2.1 | 1.8 | 1.8 | 1.9 |
| ប្រទេសកូរ៉េខាងត្បូង | 2.2 | 1.9 | 2.0 | 1.9 | 1.3 | 1.6 | 1.5 | 1.5 |
| ប្រទេសជប៉ុន | 0.2 | 0.4 | 0.4 | 0.4 | 1.1 | 0.6 | 0.7 | -- |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)


***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*



*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។ ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*